រដ្ឋសភា
ចូល លេខ ៦១០
ថ្ងៃទី ៥/១ ឆ្នាំ២០១៤ ម៉ោង ៩:៣០
បញ្ជូនទៅ

# ព្រះរាជក្រម

នស/រកម/០១១៤/០០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុនអាឡិច ឧបតើរសិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៤ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើការធានាទូទាត់របស់
# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# ឲ្យក្រុមហ៊ុនអាឡិច ឧបតើរសេិន

**មាត្រា ១.-**

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា ឲ្យក្រុមហ៊ុនអាឡិច ឧបតើរសេិន ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនអាឡិច ឧបតើរសេិន និងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី រវាងអគ្គិសនីកម្ពុជា និង ក្រុមហ៊ុនអាឡិច ឧបតើរសេិន ដែលបានចុះហត្ថលេខា នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៣។ ការធានានេះ មានអត្ថបទទាំងស្រុង ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តពល់នីតិវិធី ដើម្បីអនុវត្តលិខិតធានាទូទាត់នេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៤

នស.រកម.១៤០១.០២៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**អូន ព័ន្ធមុនីរ័ត្ន**

លេខ: ៤៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០០១.....សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣

# លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

**ជូនចំពោះ** : **លោក** Lau Yao Zhong
Alex Corporation Co., Ltd.
**អាសយដ្ឋាន**: លេខ CE4, ផ្លូវលេខ ២៦៥, សង្កាត់ទឹកល្អក់៣, ខណ្ឌទួលគោក, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
**ទូរសារ** : ៨៥៥ ២៣ ៨៦៦ ៦៦៦

**យោង** :

(ក) សិទ្ធិប្រទាន លេខ ៧២ សប្រទ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (ឧបសម្ព័ន្ធ១) ។

(ខ) កិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (ឧ.រ.ថ) និងក្រុមហ៊ុន អាឡិច ខបកើរេសិន (Alex Corporation Co., Ltd.) (ក្រុមហ៊ុន) ។

(គ) អគ្គិសនីកម្ពុជា ជាសហគ្រាសរដ្ឋ មានការទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវលេខ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (អ.ក), បានចុះកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី (PTA) ជាមួយក្រុមហ៊ុន ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ ។

(ឃ) រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមផ្តល់ ៖ (១)-ការធានាលើការទូទាត់ថ្លៃបញ្ជូនអគ្គិសនី សម្រាប់ការប្រើប្រាស់គម្រោង ១០០% (មួយរយភាគរយ) ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់ និង (២)-ការធានាលើការទូទាត់បញ្ចប់កិច្ចព្រមព្រៀង ស្របតាមកិច្ចព្រមព្រៀង PTA និង/ឬ IA និងក្នុងករណីដែលក្រុមហ៊ុន មិនអាចដំណើរការគម្រោងបាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ប្រធានសក្តិនយោបាយ ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

(ង) តាមការតម្រូវក្នុងប្រការ ៤.៨ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (ស.ហ.វ) ជំនួសមុខឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា (អ្នកធានា) បាន យល់ព្រមចុះហត្ថលេខា លើលិខិតធានាលើការទូទាត់ ដែលជាកាតព្វកិច្ចរបស់ អ.ក ឬ ឱ.រ.ថ ស្របតាម PTA និង IA ។

**ដូច្នេះ យើងខ្ញុំសូមធានា ថា ៖**

១. អ្នកធានាសូមធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យក្រុមហ៊ុន នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ ឱ.រ.ថ ឬ អ.ក ឱ្យក្រុមហ៊ុន ក្រោមកិច្ចព្រមព្រៀង IA ឬ PTA ដែល ឱ.រ.ថ ឬ អ.ក ខកខានពុំបានទូទាត់ អនុលោមតាម អាណត្តិ នៃ IA ឬ PTA (លិខិតធានា) ។

២. លិខិតធានានេះ ត្រូវជាការធានាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ ដែលត្រូវបង់ឱ្យក្រុមហ៊ុនគ្រប់ពេល ដោយ ឱ.រ.ថ ឬ អ.ក ក្រោមកិច្ចព្រមព្រៀង IA ឬ PTA ទោះជា មានលិខិតជូនដំណឹងណាមួយ ស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ឬការរំលាយ ឬអសមត្ថភាព ឬការ ផ្លាស់ប្តូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង ឱ.រ.ថ ឬ អ.ក ឬក្នុងនាម ឬរបៀប ឬការទូទាត់ គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងធ្វើសំណើសុំការទូទាត់ពីអ្នកធានា ក្រុមហ៊ុនត្រូវ ធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី ឱ.រ.ថ ឬ អ.ក ។ ក្រោយរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិក្កយបត្រ ដូចមានចែងក្នុងប្រការ ១១.១ នៃ PTA ឬសំណើ សុំទូទាត់ណាមួយពីក្រុមហ៊ុន ទៅ ឱ.រ.ថ ត្រូវបានទទួលដោយ អ.ក ឬ ឱ.រ.ថ ក្រុមហ៊ុនអាច ជូនដំណឹងទៅអ្នកធានា ជាលាយលក្ខណ៍អក្សរថា ការទូទាត់ ដោយ ឱ.រ.ថ ឬ អ.ក បានហួសកាល កំណត់ និងលើកសំណើសុំទូទាត់ពីអ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានា ត្រូវធ្វើ ការទូទាត់ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ។ ការយឺតយ៉ាវក្នុងការទូទាត់ របស់អ្នកធានា ក្រោម លិខិតធានានេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូក ៣% (បីភាគរយ) ។ ពុំមានសំណើណាមួយ ដែលធ្វើឡើងដោយក្រុមហ៊ុន ស្របតាមលិខិតធានានេះ ដែលប៉ះពាល់ ឬ ជំទាស់សិទ្ធិ របស់ក្រុមហ៊ុន ក្នុងការធ្វើសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយបត្រ ដែលមិនទាន់ ទូទាត់ផ្សេងទៀតឡើយ ។

ទឹកប្រាក់ទាំងអស់ ដែលអ្នកធានាត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនី ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំណត់ដោយក្រុមហ៊ុន ជាប្រាក់ដុល្លារអាមេរិក ឱ្យក្រុមហ៊ុន ។

៤. រាល់សំណើសុំទូទាត់ ដែលបានធ្វើឡើងតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬដោយផ្ទាល់ ដោយមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន នៅការិយាល័យរបស់ អ្នកធានា និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រី ដែលបាន ទទួលការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត បញ្ជាក់ថា ៖

"យើងខ្ញុំ សូមបញ្ជាក់ថា ៖

(១). ក្រុមហ៊ុន អាឡិច ឧបករើរសិន (ក្រុមហ៊ុន) បានធ្វើសំណើសុំទូទាត់ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ្នកធានា) នូវចំនួនទឹកប្រាក់........... {បញ្ចូលទឹកប្រាក់} ដុល្លារអាមេរិក ស្របតាមចំណុចទី១ នៃលិខិតធានារបស់រាជរដ្ឋាភិបាល លើការទូទាត់ ចុះថ្ងៃទី.......ខែ......... ឆ្នាំ២០១៣ រវាង អ្នកធានា និង ក្រុមហ៊ុន ។

(២). ចំនួនទឹកប្រាក់ខាងលើ គឺដល់កាលកំណត់ និងត្រូវទូទាត់ដោយ អ.ក ឬ ឧ.រ.ថ ស្របតាម PTA/IA រវាងក្រុមហ៊ុន និង អ.ក ឬ ឧ.រ.ថ និងពុំមានផ្នែកណាមួយនៃចំនួនទឹកប្រាក់ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃវិវាទ រវាង អ.ក ឬ ឧ.រ.ថ និងក្រុមហ៊ុន នោះទេ ។

(៣). សំណើសុំទូទាត់ពី ឧ.រ.ថ ឬ អ.ក ជាលាយលក្ខណ៍អក្សរ បានធ្វើរួចហើយ ។

(៤). ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ ឧ.រ.ថ ឬ អ.ក រហូតដល់ថ្ងៃនេះ។

៥. អ្នកធានាសូមអះអាង និងធានា នៅថ្ងៃនេះថា ៖

- អ្នកធានាមានសិទ្ធិពេញសមត្ថភាព និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា ការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេតអាណត្តិ និងបញ្ញត្តិនានា នៃលិខិតធានានេះ ។

- លិខិតធានានេះ ជាកាតព្វកិច្ចរបស់អ្នកធានា ស្របច្បាប់ មានសុពលភាព ប្រសិទ្ធភាព និងជាចំណងផ្លូវច្បាប់ អនុលោមតាមអាណត្តិ របស់លិខិតធានានេះ ។

- រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រមដែលតម្រូវឱ្យមាន ត្រូវបានទទួលរួចហើយ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិលិខិតធានានេះ ។

- កាតព្វកិច្ច និងការព្រមព្រៀងនានា របស់អ្នកធានា ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់អ្នកធានា ដែលក្នុងការអនុវត្តកាតព្វកិច្ចទាំងនេះ ជំនឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានា ត្រូវបានប្រកាន់ខ្ជាប់ ។

- អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការចុះហត្ថលេខា ការប្រគល់ និងការអនុវត្តដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ គឺជា កាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ ។

- ប្រសិនបើមានបណ្តឹងណាមួយ ចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់អ្នកធានា ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ ពុំមានអភ័យឯកសិទ្ធិណាមួយពីបណ្តឹងនោះ ត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត ។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទសាងសង់ (Construction Commencement Date) រហូតដល់ចប់អាណត្តិ នៃ IA ឬ PTA និងត្រូវបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ណាមួយ ដែល អ.ក នៅជំពាក់ក្រុមហ៊ុន ទាក់ទងនឹងអាណត្តិនេះ ឬនៅពុំទាន់ទូទាត់ ។ រីឯការធានាលើការទូទាត់លើថ្លៃបញ្ជូនអគ្គិសនី ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់សម្រាប់ការប្រើប្រាស់សមត្ថភាពគម្រោង ត្រូវមានសុពលភាពចាប់ពីថ្ងៃដែលគម្រោងដំណើរការអាជីវកម្ម ( Commercial Operation Date ) ។

៧. គ្មានការខកខាន ឬការយឺតយ៉ាវណាមួយ ដោយក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយក្រោមលិខិតធានានេះ ត្រូវបានចាត់ទុកជាការបោះបង់សិទ្ធិ ឬការដោះស្រាយនោះឡើយ ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬតែមួយផ្នែក រាំងការអនុវត្តបន្ថែម នូវសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀតឡើយ ។ គ្មានការបដិសេធណាមួយរបស់ក្រុមហ៊ុន មានប្រសិទ្ធភាពទេ លើកលែងតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ ។ សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្តល់ឱ្យក្រុមហ៊ុន ដោយលិខិតធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលត្រូវបានផ្តល់ដោយច្បាប់ឡើយ ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលត្រូវហៅកាត់រួមគ្នាថា "លិខិតជូនដំណឹង") ដែលត្រូវផ្តល់ ឬធ្វើឡើងស្របតាមលិខិតធានានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវដាក់អាសយដ្ឋានបញ្ជូនទៅបុគ្គល ដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមអ្នករត់សំបុត្រ ។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថា បានប្រគល់ ៖

(ក). ពេលបានប្រគល់ផ្ទាល់ដៃ, ឬ

(ខ). នៅពេលប្រគល់ ដោយមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួល ដោយអ្នកផ្ញើឯកសារដែលមានការទទួលស្គាល់ជាអន្តរជាតិ បញ្ជូនទៅភាគីទទួល នៅអាសយដ្ឋានដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដែលភាគីនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹង ឱ្យទៅភាគីប្រគល់លិខិត នៅអាសយដ្ឋាន ឬលេខទូរសារ ចែងខាងក្រោម) ៖

សម្រាប់ អ្នកធានា ៖

| | |
|---|---|
| ជូនចំពោះ | ៖ ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| អាសយដ្ឋាន | ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ផ្លូវលេខ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ,<br>រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា |
| ទូរសារលេខ | ៖ +៨៥៥ ២៣ ៤២៧ ៧៩៨ |

សម្រាប់ ក្រុមហ៊ុន ៖

| | |
|---|---|
| អាសយដ្ឋាន | ៖ លេខ CE4, ផ្លូវលេខ ២៦៥, សង្កាត់ទឹកល្អក់៣,<br>ខណ្ឌទួលគោក, រាជធានីភ្នំពេញ,<br>ព្រះរាជាណាចក្រកម្ពុជា |

ជូនចំពោះ ៖ ប្រធានក្រុមហ៊ុន
ទូរសាររលេខ ៖ +៨៥៥ ២៣ ៨៦៦ ៦៦៦

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត ។

៩. អ្នកជានាមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតជានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីក្រុមហ៊ុនឡើយ ហើយក្រុមហ៊ុនមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតជានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីអ្នកជានាឡើយ ។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះក្តី សម្រាប់គោលបំណងអភិវឌ្ឍន៍ ឬការផ្តល់ហិរញ្ញប្បទានអចិន្ត្រៃយ៍ដល់គម្រោង ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬបង្កើតការធានាផលប្រយោជន៍ ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតជានានេះ សម្រាប់ជាប្រយោជន៍ដល់អ្នកឱ្យខ្ចីប្រាក់ ។ លិខិតជានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានប្រសិទ្ធភាព ជាប្រយោជន៍ដល់អ្នកជានា និងក្រុមហ៊ុន ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់ របស់ភាគីនីមួយៗ ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជានា និងក្រុមហ៊ុន ក្រោម ឬអនុលោមតាមលិខិតជានានេះ ត្រូវបានគ្រប់គ្រងដោយ និងបកស្រាយ តាមច្បាប់នៃប្រទេសអង់គ្លេស ដែលនឹងត្រូវជាច្បាប់គ្រប់គ្រងមជ្ឈត្តកនិច្ឆ័យផងដែរ ។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹងលិខិតជានានេះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីភាគីមួយ បានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ អ្នកជានា និងក្រុមហ៊ុន ត្រូវដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព ។ ប្រសិនបើមិនអាចដោះស្រាយបានតាមរយៈការពិភាក្សាជាមិត្តភាពទេ ត្រូវបញ្ជូនវិវាទនោះ ទៅមជ្ឈមណ្ឌលមជ្ឈត្តកនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាន នៃមជ្ឈមណ្ឌលមជ្ឈត្តកនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអន្លើ រវាងបញ្ញត្តិនេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តកនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ បញ្ញត្តិនេះត្រូវមានប្រសិទ្ធភាព ។ សេចក្តីសម្រេច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្តីសម្រេចស្ថាពរ ជាសេចក្តីសន្និដ្ឋាន និងជាចំណងផ្លូវច្បាប់ទៅលើអ្នកជានា និងក្រុមហ៊ុន និងអាចយកមកអនុវត្ត នៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការ ធ្វើឱ្យសេចក្តីសម្រេចនោះ អនុវត្តបាន ។ ភាគីទាំងពីរត្រូវទទួលយក និងអនុវត្តសេចក្តីសម្រេចនោះ ហើយភាគីនីមួយៗ ត្រូវទម្លាក់ចោលដោយឥតលក្ខខណ្ឌ នូវសិទ្ធិណាមួយ ដែលគេអាចមាន ដើម្បីតវ៉ាអំពីសុពលភាពនៃសេចក្តីសម្រេចនោះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តកនិច្ឆ័យនោះ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយ ទៅមជ្ឈត្តកនិច្ឆ័យ ដែលលិខិតជានានេះមានប្រសិទ្ធភាពអនុវត្ត ។ រាល់ការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តកនិច្ឆ័យ ត្រូវធ្វើជាប្រាក់ដុល្លារអាមេរិក ។ ចំណាយលើមជ្ឈត្តកនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តកនិច្ឆ័យនោះ ។ ភាគីដែលទទួលខុសត្រូវទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តកនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា LIBOR បូក ៣%

(បីភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសម្រេចពីមជ្ឈត្តវិនិច្ឆ័យនោះ ដោយគិតចាប់ពីកាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច ។

១២. ពាក្យសរសេរជាអក្សរធំ ដែលបានប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតធានានេះ ត្រូវមានន័យដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ។

១៣. ប្រសិនបើបញ្ញត្តិណាមួយ ឬច្រើន ក្នុងលិខិតធានានេះ ត្រូវបានរកឃើញថា គ្មានសុពលភាព ខុសច្បាប់ ឬមិនអាចអនុវត្តបាន បញ្ញត្តិទាំងនោះ ត្រូវរក្សាតម្លៃដែលអនុញ្ញាតដោយច្បាប់ ហើយភាពគ្មានសុពលភាព ភាពខុសច្បាប់ ឬភាពមិនអាចអនុវត្តបានទាំងនោះ ពុំមានឥទ្ធិពលដល់សុពលភាព នៃបញ្ញត្តិផ្សេងទៀត នៃលិខិតធានានេះឡើយ ។

តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការកាត់កង ការទាមទារទៅវិញទៅមក ការបន្ធូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយ ដែលអ្នកធានាមាន ឬអាចមានចំពោះក្រុមហ៊ុន ត្រូវតែមានសម្រាប់អ្នកធានា ដើម្បីតតាំងជាមួយក្រុមហ៊ុន ទាក់ទងនឹងកាតព្វកិច្ចណាមួយ របស់អ្នកធានាចំពោះក្រុមហ៊ុន ក្រោមលិខិតធានានេះឡើយ ។

១៤. លិខិតធានានេះ ត្រូវផុតសុពលភាពនៅពេលបញ្ចប់ IA និង PTA ប្រសិនបើគ្មានការទាមទារ ហើយនៅរក្សាការធានានេះដដែល ក្នុងករណីមានសំណើសុំការទូទាត់ជាលាយលក្ខណ៍អក្សរណាមួយ ពីលោក បញ្ជូនមកយើងខ្ញុំ ស្របតាមលិខិតធានានេះ ដែលត្រូវតែទទួលបានដោយយើងខ្ញុំ មុនពេលនោះ ។

១៥. លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្ត បន្ទាប់ពីទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា ។

សូមលោកប្រធាន មេត្តាទទួលនូវការគោរពអាន ពីខ្ញុំ ។

រដ្ឋមន្ត្រី
[ក្រសួងសេដ្ឋ]កិច្ច និង ហិរញ្ញវត្ថុ

[គាត់]. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
-អគ្គិសនីកម្ពុជា
-ឯកសារ-កាលប្បវត្តិ



២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
No. 001 MEF/..............

Phnom Penh, November 13 , 2013

GOVERNMENT GUARANTEE OF PAYMENTS

**Mr. Lau Yao Zhong,**
**Alex Corporation Co., Ltd.**
Address : No. CE4, Street 265, Teuk Laak 3 commune, Toul Kok district, Phnom Penh, Kingdom of Cambodia.
Facsimile : +855 23 866 666

Dear Sir,

We refer to:

(A) Delegation of Full Power No. 72 D.F.P. dated 5 November 2013 by Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia. (Attachment 1).

(B) The Implementation Agreement ("IA") dated 12 November 2013, entered between the Royal Government of Cambodia ("RGC") represented by Senior Minister, Minister of Ministry of Industry, Mines and Energy ("MIME") and Alex Corporation Co., Ltd. (the "Company").

(C) ELECTRICITÉ DU CAMBODGE, a wholly state-owned limited liability enterprise incorporated by Royal Decree No. CHS/RD/0396/10 of the RGC dated 9 March 1996, with its principal office located at Street 19, Wat Phnom, Daun Penh District, Phnom Penh, in the Kingdom of Cambodia, including its successors and permitted assignees ("EDC") has entered into a Power Transmission Agreement ("PTA") with the Company dated 12 November 2013.

(D) The Royal Government of Cambodia agreed to provide: (i) a guarantee on the payment for PTA charges for 100% of the Project in the event of non-payment by EDC, and (ii) a guarantee on the payment on the termination in accordance with the PTA and/or IA and in the event that the Company is unable to operate the Project arising from the Political Force Majeure Events.

(E) It is a requirement of the Implementation Agreement in accordance with its Section 4.8, the Minister of Economy and Finance on behalf of Royal Government of Cambodia (the "Guarantor") has agreed to enter into this Guarantee of the payment obligations of EDC/MIME under the PTA and IA.



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**We hereby guarantee that:**

1. The Guarantor hereby irrevocably and unconditionally guarantees and promises to pay to the Company any and every sum of money which is due and owed by MIME or EDC to Company under the IA or PTA that MIME or EDC has failed to pay in accordance with the terms of the IA or PTA (the "Guarantee").

2. This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to the Company at any time from MIME or EDC under the IA or PTA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MIME or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the Company shall be obliged only to make demand in writing for payment from MIME or EDC. After sixty (60) days from the date of the invoice(s) as specified in Section 11.1 of the PTA or any payment demand from the Company to MIME being received by EDC or MIME, the Company may notify the Guarantor in writing that payment from MIME or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within thirty (30) Days. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent). And no demand made by the Company hereunder shall prejudice or restrict the right of the Company to make further or other demands against any other unpaid invoice(s).

   All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the Company in the Kingdom of Cambodia in US Dollars to the Company.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of the Company at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the Company stating, without the obligation to substantiate, that:

   "We hereby certify that:

   (1) Alex Corporation Co., Ltd. (the "Company") is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of U.S. Dollars ------------- [insert amount] in accordance with Section 1 of the Guarantee dated ----------------- between the Guarantor and the Company;

   (2) The amount specified above is due and payable by EDC/MIME under the PTA/IA between the Company and EDC/MIME and no part of the amount specified above is the subject of a dispute between the EDC/MIME and the Company;

   (3) Demand in writing for payment from MIME/EDC has been made;

   (4) Such amount, on the date hereof, remains unpaid by MIME/EDC."

5. The Guarantor represents and warrants that, as of the date hereof:

- The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.

- This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.

- All necessary action has been taken, and all approvals required have been obtained, under the Laws of the Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.

- The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.

- The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes our unconditional and irrevocable direct obligation.

- Should any proceedings be brought against it or its assets in any jurisdiction in relation to this Agreement, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Construction Commencement Date until the termination of the term of the IA or PTA and for so long thereafter as any amount owed to the Company by EDC in connection with such term is or may be outstanding. However, such Guarantee on PTA charges in the event of non-payment by EDC for the use of capacity of the Project shall be applicable from the Commercial Operation Date (COD) of the Project.

7. No failure or delay by the Company to exercise any right or remedy under this Guarantee shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by the Company shall be effective unless it is in writing.

   The rights and remedies of the Company provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:

   (a) when presented personally, or

   (b) upon the day of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below (or such other address as such Party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

The address for service of Notice shall be:

For the Guarantor:

| | |
|---|---|
| Attention | : Minister, Ministry of Economy and Finance |
| Address | : Ministry of Economy and Finance<br>Street No. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Kingdom of Cambodia |
| Facsimile | : +855 23 427 798 |

For the Company:

| | |
|---|---|
| Address | : No. CE4, Street 265, Teuk Laak 3 commune,<br>Toul Kok district, Phnom Penh, Kingdom of Cambodia. |
| Attention | : President |
| Facsimile | : +855 23 866 666 |

or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Company, and the Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor. Notwithstanding the provision of the immediately preceding sentence, for the purpose of development or permanent financing of the Project, the Company may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders. This Guarantee shall be binding upon and inure to the benefit of the Guarantor and the Company and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the Company under or pursuant to this Guarantee shall be governed by and construed according to the Laws of England, which shall also be the procedural law governing any arbitration.

11. If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and the Company shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. Should such dispute cannot be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and the Company and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

12. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Transmission Agreement.

13. If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, the provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee.
Subject to mutual agreement, no set-off, counterclaim, reduction, or diminution of any obligation that the Guarantor has or may have against the Company shall be available to the Guarantor against the Company in connection with any obligation of the Guarantor to the Company under this Guarantee.

14. This Guarantee shall expire upon the termination of the IA and PTA if no claim has been made and remains outstanding hereunder and any written demand made to us by you hereunder must therefore be received by us before that time.

15. This Guarantee shall become in full and effective on its ratification by legislatures of the Kingdom of Cambodia.

Yours faithfully,

**Dr. AUN PORNMONIROTH**
**Minister, Ministry of Economy & Finance**

CC :

- Ministry of the Royal Palace
- Secretariat of Senate
- Secretariat of National Assembly
- Council for the Development of Cambodia (CDC)
- Office of Council of Ministers
- Ministry of Foreign Affairs and International Cooperation
- Ministry of Industry, Mines, and Energy
- Cabinet of Samdech Akka Moha Sena Padei
  Techo HUN SEN, Prime Minister.
- Electricite du Cambodge (EDC)
- File

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧២ សលក

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- បានឃើញព្រះរាជក្រម លេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសម្បទាន
- បានឃើញអនុក្រឹត្យ លេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការសម្រេចរបស់គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣

## រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោង IMPLEMENTATION AGREEMENT (IA), និងលើលិខិតធានាទូទាត់ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា GOVERNMENTAL GUARANTEE OF PAYMENT ដោយអគ្គិសនីកម្ពុជា (EDC) និង/ឬ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទៅឱ្យក្រុមហ៊ុន ALEX CORPORATION CO., LTD. សម្រាប់គម្រោងវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី តង់ស្យុង ២៣០ គីឡូវ៉ុល ប្រវែង ១៩៨ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ទៅខេត្តព្រះសីហនុ ។

ក្នុងករណីដែលឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន ។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោម លើសិទ្ធិប្រទាននេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

*Kingdom of Cambodia*

រាជរដ្ឋាភិបាល

*Royal Government*

N. 72 DFQ

ជាតិ សាសនា ព្រះមហាក្សត្រ

*Nation Religion King*

Phnom Penh, November 5, 2013

# DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0913/903 dated 24 of September 2013 on the nomination of the Royal Government of Cambodia
- Seen the Royal Kram 02/NS/94 dated 20 of July 1994 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/1212/010 dated 26 of December 2012 promulgating the Law on Finance for Management of Fiscal Year 2013
- Seen the Royal Kram 03/NS/94 dated 05 0f August 1994 promulgating the Law on Investment of Kingdom of Cambodia and the Law on Amendment of Law on Investment of Kingdom of Cambodia promulgated by the Royal Kram NS/RKM/0303/009 dated 24 of March 2003
- Seen the Royal Kram NS/RKM/1007/027 dated 19 0f October 2007 promulgating the Law on Concessions
- Seen Sub-decree 111 អនក្រ.បក dated 27 of September 2005 on Implementation of the Law on Amendment of Law on Investment of Kingdom of Cambodia
- Referring to the decision of Council of Ministers in its plenary session on 25 October 2013

## THE ROYAL GOVERNMENT OF CAMBODIA

Delegates herewith to H.E. MR. AUN PORNMONIROTH, Minister of Economy and Finance, full power to sign the Implementation Agreement (IA), and the Governmental Guarantee of Payment by the EDC and/or MIME to ALEX CORPORATION CO., LTD. for the Development of 230kV Phnom Penh-Preah Sihanouk Transmission System Project.

These powers include the powers of delegation.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

**Prime Minister**

**Samdech Akka Moha Sena Padei Techo HUN SEN**